| ១១៨២ | ម៉ូវ ម៉ី | ១៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១១៨៣ | មិត្ត នាក | ៤២ | ប | ប៉ោយព្រីង | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៨៤ | មិន ណា | ៣៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៨៥ | មិន ម៉ាប់ | ៤២ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៨៦ | មុន ជួន | ៣២ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៨៧ | ម៉ាន ដាំ | ៧០ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៨៨ | មុយ វែង | ៣៤ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៨៩ | មូក ឡាត់ | ៧៣ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៩០ | មូក នាប | ៥៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៩១ | មូក ពាន់ | ៦៩ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៩២ | មឿន ពលូ | ២៤ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៩៣ | មឿន ចន្ធី | ១៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៩៤ | មឿន វាសនា | ២៨ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.០៦.០៧ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១៩៥ | មឿន ពលូ | ២៤ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១១៩៦ | ម៉ាន ដាំ | ៥៤ | | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១១៩៧ | ម៉ាក យ៉ុន | ៤៧ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១១៩៨ | ម៉ាក ខុន | ៤២ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១១៩៩ | មាក់ យ៉ិន | ៣៦ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០០ | ម៉ាក់ យិន | ២៣ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០១ | ម៉ាក់ យឿន | ៣៥ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០២ | មាន សេង | ៣៤ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០៣ | ភិន ស៊ីឈាង | ១៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២០៤ | នាង នន់ | ៤១ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២០៥ | ធន់ ធី | ៤៨ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០៦ | ធន់ យឺន | ៣៨ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០៧ | ធន់ លំអង | ៤៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០៨ | ធួយ គក់ | ៣១ | | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ១៦.៦.០៧ | |
| ១២០៩ | នួន សំបូរ | ២៨ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១០ | នុន យំ | ៤៧ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១១ | ប៊ូ សារ៉ៃ | ២៩ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១២ | និន សឿត | ៥២ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១៣ | និន ស៊ុម | ៤២ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១៤ | និន សែត | ៥០ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១៥ | នឿន គីមស្រ៊ី | ២៧ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១៦ | សេក វ៉ន | ២៨ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១៧ | ផាន់ សុខា | ៣២ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |
| ១២១៨ | ផាន់ សុខុម | ៤៦ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០.៦.០៧ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២១៩ | ផាន់ ហាន់ | ២៧ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២០ | ផាប់ សត់ | ២៩ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២១ | ផុន អង | ៤៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២២ | ផ្លោក ចំរុម | ២៣ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២៣ | ផ្លោក ចំរើន | ២៣ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២៤ | ធយ កក់ | ៣៧ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២៥ | និន សាន | ២៣ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២៦ | និន សី | ៤៥ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ២០,៦,០៧ | |
| ១២២៧ | លិម លឿម | ៥៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១២,១២,២០០៦ | |
| ១២២៨ | ទូន សួម | ៣៩ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ១៧,១២,០៦ | |
| ១២២៩ | សាក់ មី | ៣៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ២៤,១២,០៦ | |
| ១២៣០ | ញ៉ុក លក | ៤៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៣១ | ឆាត លឿត | ៤៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៣២ | ប៉ែន ទ្រី | ៤៣ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៣៣ | យ៉ែម ភត់ | ៤៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១,១២,២០០៦ | |
| ១២៣៤ | ស្មុត វិន | ៤៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៣៥ | សេង សួន | ២១ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៣០,៥,០៧ | |
| ១២៣៦ | ពត អឿង | ៤២ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៥,២០០៧ | |
| ១២៣៧ | អ៊ី ឆៃ | ២៦ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១៧,១២,០៦ | |
| ១២៣៨ | សេង ឌី | ៤៤ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៣៩ | ទូច គីមអ៊ី | ៤៧ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៤០ | ណាំ ឡេ | ៤០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៤១ | ថោង នី | ២៧ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៤២ | ស សុន | ៦៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១២,១២,២០០៧ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២៤៣ | ភិ រ៉ាឌី | ២១ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១,១២,២០០៦ | |
| ១២៤៤ | រ៉ាត ប៊ុនណា | ២០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១,១២,២០០៦ | |
| ១២៤៥ | ឆាំ កិល | ៥៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១,១២,២០០៦ | |
| ១២៤៦ | ឈើត ហួន | ៤៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៤៧ | យ៉ូរ ស៊ិះ | ៤៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ២៤,១២,២០០៧ | |
| ១២៤៨ | យ៉ូរ តឿង | ៣៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ២៤,១២,២០០៧ | |
| ១២៤៩ | លូញ ចែប | ៣៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ២៤,១២,២០០៧ | |
| ១២៥០ | ញ៉ូន់ ឡាំ | ៤២ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១៧,១២,២០០៦ | |
| ១២៥១ | បូង ធា | ៤៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១៧,១២,២០០៦ | |
| ១២៥២ | សេង សែន | ២០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៣០,៥,២០០៦ | |
| ១២៥៣ | សេង រុំ | ៤៥ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ០១,៥២០០៧ | |
| ១២៥៤ | ញ៉ូក់ ឡាំ | ៤៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៥៥ | ពៅ យិន | ៤០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៥៦ | ស្មុត សាខាត់ | ៤៨ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៥៧ | សៅ សារឿន | ៤៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៥៨ | សូរ រី | ៤៧ | | ស្រែះកើត | ព្រះនេត្រព្រះ | ១៧,១២,២០០៦ | |
| ១២៥៩ | យូ ឡើង | ៤៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៦០ | ញូង ម៉ៅ | ៦៣ | | ស្រែះកើត | ព្រះនេត្រព្រះ | ១២,១២,២០០៦ | |
| ១២៦១ | វ៉ាន ពៅ | ៤៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៦២ | ស្មុត កាឡៃ | ៤៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១,៥,២០០៧ | |
| ១២៦៣ | ស្មុត ហូ | ៤៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៦៤ | ស្មុត ម៉ន | ៥១ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១២,១២,២០០៦ | |
| ១២៦៥ | ហាក់ សួ | ៤៦ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥,៦,២០០៧ | |
| ១២៦៦ | ល្មុត ញៀ | ៤៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១៧,១២,២០០៦ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២៦៧ | ស្អួត ចយ | ៤៦ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៧ | |
| ១២៦៨ | ជួប បូរុះ | ២៣ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៦៩ | រឿង ហេង | ២៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៧០ | ឈួន ចេង | ២០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៧១ | ដាំ អន់សាយ | ២៦ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៧២ | លី ភ័ណ្ឌ | ២២ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៧៣ | សុខ វណ្ណ | ៣៥ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ២៤,១២,២០០៧ | |
| ១២៧៤ | ម៉ែន ធាប | ៤៦ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៩,៦,២០០៧ | |
| ១២៧៥ | ខ្លឹម ខ្លឿន | ៤៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៧៦ | ហយ កន | ៤១ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១,១២,២០០៦ | |
| ១២៧៧ | ស៊ូ គីមអាន | ៤១ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ១០,៥,២០០៧ | |
| ១២៧៨ | ស្អុត ខៀម | ៤៤ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៩,៦,២០០៧ | |
| ១២៧៩ | ចិន សារិន | ៥៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១,១២,២០០៦ | |
| ១២៨០ | ជូ ជួយ | ៥៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១២,១២,២០០៦ | |
| ១២៨១ | ឈឿន វ៉ាន់ | ២៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១២,១២,២០០៦ | |
| ១២៨២ | ម៉ន យៃ | ៤៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨,១២,២០០៦ | |
| ១២៨៣ | គុយ ហឿន | ៥២ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨,១២,២០០៦ | |
| ១២៨៤ | ង៉ា លៀត | ២៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៨៥ | ទូត ទូ | ២៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |
| ១២៨៦ | នៅ តឿ | ៤៤ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ១២,១២,២០០៦ | |
| ១២៨៧ | លឿង ឆាយ | ៤៥ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៩,៦,២០០៧ | |
| ១២៨៨ | កែវ ចាន់ | ៤៦ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ១៩,១២,២០០៦ | |
| ១២៨៩ | កិម ម៉ាញ | ៣៣ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ២៤,១២,២០០៦ | |
| ១២៩០ | សេង គ្រីម | ២៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៩,២,២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២៩១ | សេង សុន | ២៦ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១២៩២ | មុន សាញ់ | ២៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១២៩៣ | ជយម សរ៉ែង | ២៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១២៩៤ | ដាំ ឃឿង | ២២ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១២៩៥ | ដាំ ឃ្លៀង | ២៦ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១២៩៦ | មុន ប៉ាក់ | ២៦ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១២៩៧ | មុន សុក | ២៧ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១២៩៨ | ពេជ្រ រស់ | ៥៣ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១.១២.២០០៦ | |
| ១២៩៩ | ង៉ា យួន | ២៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១៣០០ | ហួន់ វ៉ា | ២៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១៣០១ | ជុរ សារុំធ | ៤៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៦ | |
| ១៣០២ | ម៉ៃ រួត | ២៦ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៦ | |
| ១៣០៣ | លួត យួន | ២៨ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៦ | |
| ១៣០៤ | ធិន លៀង | ៥៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៦ | |
| ១៣០៥ | វ៉ាត់ សារ៉ាយ | ៣០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៦ | |
| ១៣០៦ | គិប រិន | ៥២ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ១២.១២.២០០៦ | |
| ១៣០៧ | ហែម សារូ | ២២ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ១៧.១២.២០០៦ | |
| ១៣០៨ | ហយ គឿន | ៤១ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១១.១២.២០០៦ | |
| ១៣០៩ | ស៊ាន ឆោម | ៤៧ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ១១.១២.២០០៦ | |
| ១៣១០ | អៀន ប៉ាន់ | ៣៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ១០.១២.២០០៦ | |
| ១៣១១ | តំ វឿន | ៣៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ២៤.០២.២០០៦ | |
| ១៣១២ | យូ ណៃ | ៤៣ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥.៦.២០០៧ | |
| ១៣១៣ | ទិត ង៉ា | ២៥ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១៣១៤ | អឿង ឆៃ | ២៥ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣១៥ | ធុ សែយឿន | ២៦ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១៣១៦ | កោ ពេញ | ៤៧ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣១៧ | សេង ឡៅ | ៣៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣១៨ | មាស យឿង | ៣៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣១៩ | ញ៉ែម លឹត | ៦០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣២០ | នស់ ឃឿង | ៤៧ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣២១ | សុត សី | ៣៤ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣២២ | លី សី | ៣៣ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣២៣ | តាំ សល់ | ៤៨ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣២៤ | ស ង៉ូវ | ៦០ | ប | ស្រែះកើត | ព្រះនេត្រព្រះ | ៨.១២.២០០៧ | |
| ១៣២៥ | វ៉ាត ម៉ៅ | ២៨ | ស | ស្រែះកើត | ព្រះនេត្រព្រះ | ៥.២.២០០៨ | |
| ១៣២៦ | សុន ធីត | ២៧ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣២៧ | ស៊ុត ដុំ | ២០ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣២៨ | សឿន ថន | ២២ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣២៩ | សឿម យុង | ២២ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣០ | ផ្លោក ផាន់រុំ | ២២ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣១ | ខែត សុខុន | ១៨ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣២ | រ៉ែ ចិន | ២៣ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣៣ | អុន ស៊ីដែង | ១៩ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣៤ | ខែត សុខន | ១៩ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣៥ | សុន សៅ | ១៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣៦ | ហិន ថុងស៊ី | ១៨ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣៧ | សុង ស៊ីណាំង | ២៣ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៣៨ | ញ៉ូវ ឡឿន | ២២ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣៣៩ | ឈុន សីហា | ២០ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៤០ | ញៀត ស្រីដុះ | ២០ | ប | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៤១ | ម៉ាក់ ញ៉ៀត | ២២ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |
| ១៣៤២ | កាន់ សុគេន | ១៩ | ស | ប៉ោយតាប៉ែន | ព្រះនេត្រព្រះ | ៧.២.២០០៧ | |

ស្រី 618 នាក់

ស្រែះខាងលិច, ថ្ងៃទី.17......ទី.....10.......ឆ្នាំ ២០០៨

ប្រធានគណៈកម្មករសហគមន៍នៃសាទ

ខៀវ សំបូរ

## បញ្ជី[redacted]ាះគណៈកម្មការសហគមន៍នេសាទ

## របាលលិចស្រែះ

## ឃុំ ព្រះនេត្រព្រះ ស្រុក ព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

| ល.រ | នាម និងគោត្តនាម | ភេទ | អាយុ | ភូមិ | តួនាទី |
|---|---|---|---|---|---|
| ១ | ខៀវ សំបូរ | ប្រុស | ៥៧ | ស្រែះខាងលិច | ប្រធាន |
| ២ | ភុំ សុផល | ប្រុស | ៣៤ | ស្រែះខាងកើត | អនុប្រធាន |
| ៣ | ព្រំ ប្រសើរ | ប្រុស | ៣២ | ស្រែះខាងលិច | លេខាធិការ |
| ៤ | ឡិប សុខុម | ប្រុស | ៣៧ | ស្រែះខាងលិច | លេខាធិការ |
| ៥ | ស៊ឹង ទូច | ស្រី | ៥៨ | ស្រែះខាងលិច | បេឡា |
| ៦ | ផាត់ គឿត | ប្រុស | ៣៤ | ប៉ោយព្រីង | ផ្សព្វផ្សាយ |
| ៧ | កាត គឿន | ប្រុស | ៤១ | ស្រែះកើត | ផ្សព្វផ្សាយ |
| ៨ | អ៊ុយ ស៊ើត | ប្រុស | ៤៣ | ស្រែះគោកស្រុក | ល្បាត |
| ៩ | កោ ពេញ | ប្រុស | ៣៩ | ស្រែះខាងកើត | ល្បាត |
| ១០ | ហ៊ី ហឿល | ប្រុស | ២៨ | ស្រែះគោកស្រុក | ល្បាត |
| ១១ | បូ ពាន់ | ប្រុស | ២៨ | ស្រែះគោកស្រុក | ល្បាត |

ធ្វើនៅ ស្រែះខាងលិច, ថ្ងៃទី...12...ខែ...10....ឆ្នាំ ២០០៨

ប្រធានគណៈកម្មការសហគមន៍នេសាទ

ខៀវ សំបូរ

បានឃើញ និងបញ្ជាក់ថា : ឈ្មោះនៅក្នុងបញ្ជី

ខាងលើ ពិតជាសមាជិកគណៈកម្មការសហគមន៍នេសាទ

របាលលិចស្រែះពិតប្រាកដមែន ។

ព្រះនេត្រព្រះ , ថ្ងៃទី ........ខែ..........ឆ្នាំ ២០០៨

**មេឃុំ**

ឡុង ហឿយ

# រចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ រហា[redacted]ង[redacted]ចស្រែះ

**ប្រធាន**
ខៀវ សំបូរ

**អនុប្រធាន**
ភុំ សុផល

**លេខាធិការ**
ព្រុំ ប្រសើ

**លេខាធិការ**
ឡិប សុខុម

**បេឡា**
ស៊ីង ទូច

**អប់រំផ្សព្វផ្សាយ**
ផាត់ ភឿត

**អប់រំផ្សព្វផ្សាយ**
កាត តឿន

**ល្បាត**
អ៊ុយ សឹត

**ល្បាត**
កោ ពេញ

**ល្បាត**
បូ ពាន់

**ល្បាត**
ហ៊ី ហឹល

ព្រះរា[redacted]ចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ
# របាលខាងលិចស្រែះ

ភូមិ : ប៉ោយព្រីង ប៉ោយតាប៉ែន ស្រែះគោកស្រុក ស្រែះខាងលិច ស្រែះខាងកើត

ឃុំ : ព្រះនេត្រព្រះ

ស្រុក : ព្រះនេត្រព្រះ

ខេត្ត : បន្ទាយមានជ័យ

## ជំពូកទី ១

## គោលបំណង និងនាមករណ៍

**ប្រការ ១.-**

លក្ខន្តិកៈនេះមានគោលបំណង ÷

- កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ ការប្រើប្រាស់ធនធានជលផល របស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព
- ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ
- ការពារសិទ្ធិ និងផលប្រយោជន៍របស់សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ ។

**ប្រការ ២.-**

ឈ្មោះសហគមន៍នេសាទ **រហាលខាងលិចស្រះ**ហៅកាត់ថា **ស.ន.រ.ហ.ស**អាសយដ្ឋាន ភូមិ ស្រះខាងលិច ឃុំ ព្រះនេត្រព្រះ ស្រុក ព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

សហគមន៍នេសាទនេះ មានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង :

១- ភូមិប៉ោយព្រីង ឃុំ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

២- ភូមិប៉ោយតាប៉ែន ឃុំ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៣- ភូមិស្រះគោកស្រុក ឃុំ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៤- ភូមិ ស្រះខាងលិច ឃុំ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

៥- ភូមិស្រះខាងកើត ឃុំ ព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

**មានកម្មវត្ថុ:** ដើម្បីរួមចំណែកក្នុងការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ ការប្រើប្រាស់ធនធានជលផល និងសត្វព្រៃប្រកបដោយនិរន្តរភាព។

## ជំពូកទី ២

## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣.-**

ប្រជាពលរដ្ឋទាំងពីរភេទដែលមានគោលបំណងចងចូលជាសមាជិកសហគមន៍នេសាទ មានសិទ្ធិដាក់ពាក្យសុំចូល ដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើង។

**ប្រការ ៤.-**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើ មានសិទ្ធិ ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះជាបេក្ខជននៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ច សង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់
- ធ្វើនេសាទជាលក្ខណៈគ្រួសារស្របតាមច្បាប់ស្តីពីជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការ គ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធវិស័យជលផល
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចរដ្ឋបាលជលផល ក្រុមប្រឹក្សាឃុំ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ
- ទទួលការគាំទ្រពីមជ្ឈដ្ឋាននានាដើម្បីផលប្រយោជន៍របស់សហគមន៍ ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរាល់សកម្មភាពរៀងៗខ្លួន និងរួមគ្នាចំពោះកំហុស ដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកពហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួន មួយភាគដប់ (១/១០) ឡើងទៅ អាចស្នើសុំឱ្យប្រធាន គណៈកម្មការសហគមន៍នេសាទ បញ្ចូលបញ្ហាមួយចំនួន ទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ របស់គណៈកម្មការ សហគមន៍នេសាទសាមី ហើយចំនួន សមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះអាចចាត់ តំណាង ចំនួន បី(៣) នាក់ ចូលរួមប្រជុំដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទ នូវបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងចំណុចដែលបានស្នើឡើង នោះ។

**ប្រការ ៥.-**

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារកិច្ចដូចខាងក្រោម ÷

- អនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល
- អនុវត្តតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- អនុវត្តតាមអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ
- អនុវត្តតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

- អនុវត្តតាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- បង់ប្រាក់សមាជិកភាពចំនួន ១០០០ រៀល ចំពោះអ្នកដែលទើបមានអាយុ ១៨ឆ្នាំ និង ៣០០០ រៀល ចំពោះអ្នកមានដែលអាយុចាប់ពី ១៩ ឆ្នាំឡើង ដោយដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- បង់ប្រាក់ភាគទានប្រចាំឆ្នាំចំនួន ១៥០០ រៀល ក្នុងម្នាក់
- ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីផលប្រយោជន៍ និងការរីកចំរើនរបស់សហគមន៍នេសាទ
- ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ
- ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍ រាល់សកម្មភាពបទល្មើសជលផល ក្នុងកន្លែងនេសាទ សហគមន៍ ។

## ជំពូកទី ៣

## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និង ការបណ្តេញចេញពីសមាជិក

**ប្រការ ៦.-**

សមាជិកសហគមន៍នេសាទ មានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ ÷

- ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ
- ការផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេសាទសហគមន៍
- សាមីខ្លួនទទួលមរណៈភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៧.-**

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម ÷

- ការមិនបង់ភាគទានចំនួន ០៣ លើកជាប់ៗគ្នា
- ការធ្វើឱ្យប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍នៃសហគមន៍នេសាទ ឬសមាជិកសហគមន៍នេសាទដទៃទៀត
- សាមីខ្លួនត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម
- សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ។

## ជំពូកទី ៤

## របៀបរបបការបញ្ជី និង ឯកសារនានា

**ប្រការ ៨.-**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ÷

- ភាគទានរបស់សមាជិកសហគមន៍នេសាទ

- អំណោយពីសប្បុរសជន

- ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល

- ចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ៩.-**

រាល់ការចំណាយថវិកា សហគមន៍នេសាទ ត្រូវអនុវត្តដូចតទៅ ÷

- ការចំណាយពី ១រៀល ដល់ ៥០ ០០០រៀល ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ

- ការចំណាយពី ៥០ ០០១រៀល ដល់១៥០ ០០០រៀល ត្រូវសម្រេចដោយគណៈកម្មការសហគមន៍នេសាទ

- ការចំណាយពី ១៥០ ០០១រៀល ឡើងទៅ ត្រូវសម្រេចដោយមហាសន្និបាត ។

**ប្រការ ១០.-**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំឱ្យមានបញ្ជី ÷

- ចំណូល ចំណាយថវិកា

- សារពើភ័ណ្ឌ

- សមាជិកសហគមន៍នេសាទ

- កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ

- កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ

- ឯកសារដទៃទៀត ដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

**ប្រការ ១១.-**

ការគ្រប់គ្រង និងប្រើប្រាស់ថវិកា ÷

- ការគ្រប់គ្រងថវិកា ត្រូវមានការកាន់បញ្ជីគណនេយ្យ

- ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ

- រាល់ថវិកាចំណាយ ត្រូវមានរបាយការណ៍ទូទាត់ដោយមានសក្ខីបត្រ និងចុះបញ្ជីឱ្យបានត្រឹមត្រូវ

- ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបម្រើឱ្យការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍ សហគមន៍នេសាទ

- ថវិកាពិន័យបានមកពីការចូលរួមសហការណ៍បង្ក្រាបបទល្មើសនេសាទ ត្រូវបែងចែកដូចខាងក្រោម :

ក- ចំនួន៥០% សម្រាប់បង់ចូលថវិការដ្ឋ

ខ-ចំនួន ៣០% សម្រាប់បង់ចូលបេឡាសហគមន៍នេសាទ

គ-ចំនួន ២០% សម្រាប់រង្វាន់អ្នកមានស្នាដៃ

## ជំពូកទី ៥

## គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១២.~**

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការមួយរូប និងសមាជិកទទួលបន្ទុកហិរញ្ញិកមួយរូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង ។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល។ អនុប្រធានគណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

**ប្រការ ១៣.~**

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥)ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុត កំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុង មហាសន្និបាតឱ្យចូលកាន់តំណែងជំនួស។ ក្នុងករណីដែលសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុដំណើរការមិនល្អ ឬអសមត្ថភាព ក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍នេសាទចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ ជាថ្មី។

**ប្រការ ១៤.~**

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាម្នាក់អវត្តមាន ដោយគ្មាន មូលហេតុរយៈពេលប្រាំមួយ (០៦)ខែ ឬសុំលាលែងមុនចប់អាណត្តិ បេក្ខជនដែលមានឈ្មោះតាមសម្លេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើស ក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស។

## ជំពូកទី ៦

## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥.~**

គណៈកម្មការសហគមន៍នេសាទត្រូវកំណត់របបប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ ។ កិច្ចប្រជុំរបស់គណៈកម្មការ សហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាតែមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ (ពីរភាគបី) នៃសមាជិករបស់គណៈកម្មការសហគមន៍នេសាទទាំងមូល ។

**ប្រការ ១៦.–**

ប្រធានគណៈកម្មការសហគមន៍នេសាទ ជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអវត្តមាន អនុប្រធានដែលត្រូវបានប្រគល់សិទ្ធិ ត្រូវធ្វើជាប្រធានអង្គប្រជុំ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់ ។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយលក្ខណៈប្រជាធិបតេយ្យ មានរបៀបរៀបរយ និងគ្មានការរំខាន។

ប្រធានអង្គប្រជុំ អាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ។

**ប្រការ ១៧.–**

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ ។ក្នុងករណីដែលមានសម្លេងស្មើគ្នាមតិប្រធានអង្គប្រជុំជាឧត្តមានុភាព។

- សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ
- ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស
- ការទទួលពាក្យសុំចូលជាសមាជិកថ្មី
- ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុងដល់សមាជិកសហគមន៍នេសាទ

បន្ទាប់ពីកិច្ចប្រជុំចប់ភ្លាមប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសម្រេចរបស់ខ្លួន។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ត្រូវបិទផ្សាយជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ ក្នុងរយៈពេល ៧ ថ្ងៃ យ៉ាងយូរ បន្ទាប់ពីការប្រជុំ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨.–**

មហាសន្និបាតសហគមន៍នេសាទ ជាអង្គប្រជុំកំពូល ដើម្បីធ្វើការអនុម័ត និងធ្វើសេចក្តីសម្រេចទាំងឡាយក្នុងនាមសហគមន៍នេសាទ ។មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទត្រូវប្រារព្ធឡើង បន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផល តាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យស្នើសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និង កិច្ចការសំខាន់ដូចខាងក្រោម ÷

- អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ
- ឈ្មោះសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ។
- ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៩.~**

មហាសន្និបាតសាមញ្ញត្រូវរៀបចំឡើង ១ ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗរបស់សហគមន៍នេសាទ ។ក្នុងករណីចាំបាច់សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទចំនួន ភាគបី (១/៣) យ៉ាងតិច ។

**ប្រការ ២០.~**

គណៈកម្មការសហគមន៍នេសាទ អាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬសម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ ។

**ប្រការ ២១.~**

លក្ខខណ្ឌនៃដំណើរការមហាសន្និបាតមានដូចខាងក្រោម ÷

- ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ និងទីស្នាក់ការសហគមន៍នេសាទ
- ការកោះអញ្ជើញសមាជិកសហគមន៍នេសាទ ឱ្យចូលរួមមហាសន្និបាតសាមញ្ញ ត្រូវធ្វើឡើងដប់(១០) ថ្ងៃយ៉ាងតិច មុនថ្ងៃបើកមហាសន្និបាត និងបី(៣) ថ្ងៃយ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ ។
- មហាសន្និបាតសាមញ្ញ ឬវិសាមញ្ញ អាចប្រជុំពិភាក្សាអនុម័ត និងសម្រេចបានលុះត្រាតែមានវត្តមានលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ ។
- អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែល ជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន
- មហាសន្និបាតត្រូវអនុមត័លេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជី វត្តមាន

- លេខាកត់ត្រា និងប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ
- សមាជិកម្នាក់មានសំឡេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ
- សេចក្តីសម្រេចរបស់មហាសន្និបាតត្រូវយកសំឡេងលើសពីពាក់កណ្តាលនៃចំនួនសមាជិកដែលមានវត្តមាន ។

**ប្រការ ២២.-**

មហាសន្និបាតអនុម័ត ÷

- សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី ៣ នៃលក្ខន្តិកៈនេះ
- កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- ការសុំលាលែង ឬការបណ្តេញចេញពីសមាជិកភាព ឬពីសមាជិកគណៈកម្មការសហគមន៍នេសាទ
- របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ
- គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ ។

## ជំពូកទី ៨
## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣.-**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះត្រូវអនុម័តដោយមហាសន្និបាត ។

**ប្រការ ២៤.-**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទគឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះ ឆ្នោត មានសមាសភាពពីបី (៣) ទៅប្រាំ(៥)នាក់ ដែលមានប្រធាន អនុប្រធាន និងសមាជិក តាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។គណៈកម្មការរៀបចំការបោះឆ្នោតត្រូវធ្វើការប្តេជ្ញាចិត្តបង្ហាញពីភាពស្មោះត្រង់ ។

**ប្រការ ២៥.-**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ច ដូចខាងក្រោម÷

- ប្រកាសបេក្ខជនឈរឈ្មោះ
- ណែនាំអំពីនីតិវិធីនៃការបោះឆ្នោត

- បង្ហាញរូបចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ
- រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតីដើម្បីប្រកាសជូនមហាសន្និបាត ។
- ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦.-**

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលតួនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការសហគមន៍នេសាទតាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំឡេងគាំទ្រស្មើគ្នាត្រូវជ្រើសរើសស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ។

## ជំពូកទី ៩
## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និង នីតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧.-**

ការរំសាយសហគមន៍នេសាទ ត្រូវផ្អែកតាម ÷

- សំណើរបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀង កន្លែងនេសាទសហគមន៍
- សេចក្តីសម្រេចមហាសន្និបាត

ក្រោយពីរំសាយសហគមន៍នេសាទ ទ្រព្យសម្បត្តិរបស់សហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាត លើកលែងតែដែននេសាទដែលត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨.-**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទមានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

**ប្រការ ២៩.-**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

- គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួល និងដោះស្រាយរាល់វិវាទដែលកើតមានឡើងនៅក្នុង

សហគមន៍នេសាទរបស់ខ្លួន

-ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផលដើម្បីដោះស្រាយ ទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធតាមការចាំបាច់ ។

- ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមីដើម្បីដោះស្រាយតាមផ្លូវច្បាប់។

**ប្រការ ៣០.-**

សមាជិកសហគមន៍នេសាទរូបណាដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះត្រូវទទួលទណ្ឌកម្មពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទ ទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន។

## ជំពូកទី ១០

## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១.-**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង សហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត។ ការលើកសំណើកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ត្រូវធ្វើឡើងដោយសមាជិកយ៉ាងតិចមួយភាគបី (១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការ សហគមន៍នេសាទ មួយខែមុនបើកមហាសន្និបាត។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះ អាចកែប្រែបាន លុះត្រាតែមានសំឡេង យល់ព្រមលើសពីពាក់កណ្តាលនៃសមាជិកមហាសន្និបាតសហគមន៍នេសាទ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៣២.-**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទ លើកដំបូង នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០០៨ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅស្រះខាងលិច. ថ្ងៃទី17 ខែ .10... ឆ្នាំ ២០០៨

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ រហាលលិចស្រះ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

ដើម្បីធានាការគ្រប់គ្រងសហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធភាព និងមានរបៀបរៀបរយល្អ សហគមន៍នេសាទ រហាលលិចស្រេះ សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម÷

**ប្រការ ១.\~**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់ សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗ សម្រាប់បម្រើឱ្យការរីកចម្រើនរបស់សហគមន៍នេសាទ ។

**ប្រការ ២.\~**

គណៈកម្មការ សមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ច ធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ÷

- ចំពោះសមាជិកសហគមន៍នេសាទ ឬបុគ្គលដទៃទៀតត្រូវសង ឬទូទាត់ទៅតាមទំហំនៃការខូចខាតជាក់ស្តែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការ សហគមន៍នេសាទ ។ក្នុងករណីមិនព្រមសងត្រូវដាក់ជូន មហាសន្និបាតសម្រេច ។
- ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសង ឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត ។

ប្រសិនបើនីតិវិធីខាងលើនេះនៅតែមិនអាចដោះស្រាយបាន គឺត្រូវអនុវត្តតាមផ្លូវច្បាប់ និងបទបញ្ជាជាធរមាន ។

**ប្រការ ៣.\~**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាត និងរាល់កិច្ចប្រជុំរបស់សហគមន៍នេសាទតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូល រួមប្រជុំចំនួន ០៣ដង ជាប់គ្នាដោយគ្មានមូលហេតុច្បាស់លាស់ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ ។

ករណីនៅតែមិនរាងចាល គណៈកម្មការត្រូវធ្វើសំណើទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព ។

**ប្រការ ៤.\~**

សិទ្ធិដាក់ទណ្ឌកម្ម ÷

**ក- គណៈកម្មការសហគមន៍នេសាទ**

- អប់រំ ណែនាំលើកទី១ លើកទី២ លើកទី៣
- ព្រមានផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ
- ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ

- បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច
- ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅសមត្ថកិច្ចរដ្ឋបាលជលផល ចំពោះការនេសាទលើសទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងនៅក្នុងកន្លែងនេសាទសហគមន៍។

**៩- មហាសន្និបាត**

- អនុម័តការបណ្តេញចេញដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ
- សម្រេចលើសំណងការខូចខាតទ្រព្យសម្បត្តិសហគមន៍នេសាទ
- សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ
- ដាក់ទណ្ឌកម្មដល់សមាជិក ឬបុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន។

## ប្រការ ៥.-

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទ អំពីសំភារៈ ឧបករណ៍នេសាទដែលគ្រួសារនីមួយៗ ប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍។

## ប្រការ ៦.-

សមាជិកសហគមន៍នេសាទអាចប្រើប្រាស់ឧបកាណ៍នេសាទជាលក្ខណៈគ្រួសារនៅក្នុងរដូវបើកនេសាទ និងបិទនេសាទដូចមាន ចែងខាងក្រោម :

**ប្រភេទ ទំហំ ចំនួន ឧបករណ៍នេសាទ ដែលអនុញ្ញាតឱ្យប្រើប្រាស់ នៅក្នុងកន្លែងនេសាទសហគមន៍**

| ល.រ | ឈ្មោះឧបករណ៍នេសាទ | អនុញ្ញាតឱ្យប្រើប្រាស់ | |
|---|---|---|---|
| | | រដូវបើក | រដូវបិទ |
| ១ | សន្ទូចរនង | ៥០០ | ២៥០ |
| ២ | សន្ទូចបង្កៃដោត | ១០០ | ៥០ |
| ៣ | សន្ទូចបបក់ | ១ | ១ |
| ៤ | សមផ្លែបី គ្មានកែវឆ្នុះ | ១ | ១ |
| ៥ | មងរាយក្រឡាជាង ២.៥ - ៤ ហ៊ុន | ៤០០ | ២០០ |

| | | | |
|---|---|---|---|
| ៦ | សំណាញ់ ៧ហត្ថក្រឡា២ហ៊ុន | ១ | ១ |
| ៧ | លបកញ្ចុះផ្សំព្រួល ៥ម៉ែត្រ | ៤គូ | 0 |
| ៨ | លបព្រាង ផ្សំព្រួល ៥ម៉ែត្រ | ១៥ | ១០ |
| ៩ | អន្លង់ត្រីលោត | ៣ | 0 |
| ១០ | លាន់ | ៣០ | ១៥ |
| ១១ | ជួដាក់អន្ទង់ | ៣០ | ១៥ |
| ១២ | ជុច មុខ ២០តឹក | ៥០ | ៥ |
| ១៣ | តុម | ១០ | ៥ |
| ១៤ | អង្រុតធម្មតា និង អួសគន | ១ | ១ |
| ១៥ | ឈ្នាងជញ្ជាត់ ( មុខបីតឹក) | ១ | ១ |
| ១៦ | ស្ទូរផ្លែមួយ, ច្បូក, សាង គ្មានកែវឆ្លុះ | ១ | ១ |
| ១៧ | កង្វារត្រីឆ្លូញផ្លែមួយ | ១ | ១ |
| ១៨ | ចំរប់អន្ទង់ | ១ | ១ |
| ១៩ | អញ្ចង មុខ ៣ ម៉ែត្រ | ១ | ១ |
| ២០ | ឈិបរុញដោយដៃ | ១ | ១ |
| ២១ | លបកង្កែប | ១០ | ៥ |
| ២២ | ទ្រូកំពឹស | ២០ | ១០ |
| ២៣ | ទ្រូកំប៉ោង | ១០ | ៥ |
| ២៤ | កង្វារកង្កែប | ១ | ១ |
| ២៥ | កន្ទ្រងកង្កែប | ១ | ១ |
| ២៦ | សន្ទូចស្ទូចត្រីដោយដៃ | ៥ | ៥ |
| ២៧ | តុមកណ្ដេះឡង់ | ១៥០ | ១០០ |
| ២៨ | សាប | ១ | ១ |
| ២៩ | មងរៃ ឬមងទ្រោល ឬមងវាត់ | ១០ម | ១០ម |

| | | | |
|---|---|---|---|
| ៣០ | ចវ៉ | ១ | ១ |
| ៣១ | ថ្នងគាង | ១ | ១ |
| ៣២ | លបត្រីឆ្អញ | ១០ | ៥ |
| ៣៣ | សៃយឹនកំពីស | ១០ | ១០ |
| ៣៤ | កន្សុំ | ១០ | ១០ |

**ប្រភេទ ទំហំ ចំនួន ប្រវែងឧបករណ៍នេសាទក្នុងតារាងនេះ នឹងត្រូវកែសម្រួលតាមខ្លឹមសារប្រកាស របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ស្តីពី ឧបករណ៍នេសាទ ដែលចេញថ្មី**

**ប្រការ ៧.~**

សមាជិកសហគមន៍នេសាទដែល :

- ប្រព្រឹត្តិផ្ទុយ ឬរារាំង មិនឱ្យសមាជិកដទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិកៈត្រូវព្យួរសមាជិកភាពដោយ គណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាពដោយមហាសន្និបាត
- មិនចូលរួមថែរក្សាការពារធនធានជលផល ឬមិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផល ត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ
- ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ កាប់ឆ្ការ រានព្រៃលិចទឹក ត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ស្តីពីជលផល
- ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច
- អនុវត្តផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅរដ្ឋបាលជលផលមានសមកិច្ចដើម្បីដោះស្រាយតាមច្បាប់ ។

**ប្រការ ៨.~**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយធ្វើកិច្ចសន្យា និងគោរព កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបានគោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ ។

**ប្រការ ៩.-**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍លើកទី២ នៅថ្ងៃទី ២៤......ខែ.តុលា..... ឆ្នាំ២០០៨ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាដោយប្រធានគណៈកម្មការសហគមន៍នេសាទ។

ធ្វើនៅស្រះខាងលិច,ថ្ងៃទី ១២ ខែ ១០ ឆ្នាំ ២០០៨

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍អំពីគោលបំណងនៃការបង្កើត និងគ្រប់គ្រងធនធានជលផល របស់សហគមន៍នេសាទ រហាលលិចស្រះ

ក្រោយពីមានការកែទំរង់លើវិស័យជលផល រាជរដ្ឋាភិបាលបានកាត់ផ្ទៃឡូតិ៍នេសាទទុកសំរាប់ប្រជាពលរដ្ឋស្មើនឹង ៨៦% នៃផ្ទៃក្រលាឡូតិ៍នេសាទទាំងអស់ក្នុង ខេត្តបន្ទាយមានជ័យ ផ្តល់ជូនប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណៈគ្រួសារ ។

យើងខ្ញុំសូមគោរពជំរាប ឯកឧត្តមប្រធានរដ្ឋបាលជលផលជ្រាបថា ការផ្តួចផ្តើមបង្កើតសហគមន៍នេសាទនេះ កើតឡើងក្រោយពីភាពតានតឹង នៃជីវភាពរស់នៅរបស់ប្រជានេសាទ ដែលបណ្តាលមកពីដែននេសាទតូចចង្អៀតភាព អណាធិបតេយ្យនៃការនេសាទខុសច្បាប់ និងទំនាស់ដែននេសាទធ្វើឱ្យប្រជាពលរដ្ឋក្នុងភូមិទាំងប្រាំ ក្នុងឃុំព្រះនេត្រព្រះ បានឯកភាពគ្នាធ្វើសំណើរដោយបានព្រមព្រៀងគ្នាបង្កើតសហគមន៍នេសាទនេះឡើង ក្នុងគោលបំណងចូលរួមចំណែក គ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍន៍ដែនសហគមន៍នេសាទ។ បន្ទាប់ពីមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រជាជនភូមិប៉ោយព្រីង ភូមិប៉ោយតាប៉ែន ភូមិស្រះគោកស្រុក ភូមិស្រះខាងលិច និងភូមិស្រះខាងកើត និងភូមិដែលនៅជាប់ភូមិសាស្ត្រ ត្រូវបានបើកទូលាយឱ្យប្រជាពលរដ្ឋក្នុងភូមិ មានសិទ្ធិប្រកបមុខរបរនេសាទគ្រួសារ ។ សហគមន៍នេសាទ រហាលលិចស្រះ ត្រូវបានបង្កើតឡើងដោយការិយាល័យជលផល ខេត្តបន្ទាយមានជ័យ ដោយមានការជួយជ្រោមជ្រែងពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ ។ គណៈកម្មការសហគមន៍នេសាទ រហាលលិចស្រះ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយសេរី យុត្តិធម៌ និងសំងាត់ ចេញពីប្រជាពលរដ្ឋមូលដ្ឋានក្នុងភូមិ ។ សហគមន៍នេសាទ រហាលលិចស្រះ ដឹកនាំដោយគណៈកម្មការសហគមន៍នេសាទ ដែលមានគណៈកម្មការ សរុបចំនួន ១១ នាក់ (ស្រី ០១ នាក់) ត្រូវបាន ជ្រើសរើសឡើងតាមរយៈការបោះឆ្នោតដោយសេរី យុត្តិធម៌ និងសំងាត់ ចេញពីប្រជាពលរដ្ឋមូលដ្ឋានភូមិ ភូមិប៉ោយព្រីង ភូមិតាប៉ែន ភូមិស្រះគោកស្រុក ភូមិស្រះខាងលិច និងភូមិស្រះខាងកើត និងរហូតមកដល់ពេលនេះ សហគមន៍នេសាទ រហាលលិចស្រះ មានសមាជិកសហគមន៍ចូលរួមចំនួន ១៣៤២ នាក់ ក្នុងនោះស្រីមានចំនួន៦១៨ នាក់ និងមានផែនទីកន្លែងនេសាទសហគមន៍ដែលត្រូវគ្រប់គ្រងសរុប ២១៦៨ហិចតា ក្នុងនោះកន្លែងអភិរក្សមានទំហំ ១០ហិតា ។

ចាប់តាំងពីឆ្នាំ ២០០៧ រហូតមកដល់បច្ចុប្បន្ននេះសហគមន៍នេសាទ រហាលលិចស្រះ បានបន្ថែមលើការពង្រឹងសមត្ថភាពសហគមន៍នេសាទជាមួយនឹងគំរោងមួយថ្មីទៀតរបស់រាជរដ្ឋាភិបាលគឺ **គំរោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប-** ផ្នែកទី២ តាមរយៈមន្ត្រីការិយាល័យជលផល ដែលជាផ្នែកអនុវត្តគំរោង ក្រោមជំនួយបច្ចេកទេសរបស់អង្គការ FAO ។

ចាប់តាំងពីចាប់ផ្តើមបង្កើតសហគមន៍នេសាទក្នុងឆ្នាំ២០០៣ រហូតមកដល់សព្វថ្ងៃ សហគមន៍នេសាទយើងខ្ញុំបាន

ខិតខំប្រឹងប្រែងធ្វើការងារសំខាន់ជាច្រើនដូចជា ការបង្កើតគណៈកម្មការសហគមន៍នេសាទ ការផ្សព្វផ្សាយដើម្បីបង្កើន ការចូលរួមពីប្រជាជនក្នុងការគ្រប់គ្រងធនធានជលផល ការងារល្បាតបង្ក្រាបបទល្មើសនេសាទ ទប់ស្កាត់ការពង្រីកដីកសិកម្មតាមមាត់បឹង អូរ ស្ទឹង បង្កើតតំបន់អភិរក្ស ។ល។ ទន្ទឹមនឹងនេះ សហគមន៍យើងខ្ញុំបានរៀបចំឯកសាររួចរាល់ជាស្ថាពរ ដូចមានចែងក្នុងអនុក្រឹត្យសហគមន៍នេសាទ ដែលរួមមាន បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង និងផែនទីកន្លែងនេសាទសហគមន៍ កិច្ចព្រមព្រៀងផែនការគ្រប់គ្រង ។ ដើម្បីឱ្យយន្តការគ្រប់គ្រង និងដឹកនាំស្របតាមលក្ខណៈច្បាប់ សហគមន៍នេសាទរហាលលិចស្រែះ បានរៀបចំមហាសន្និបាតសហគមន៍ដើម្បីអនុម័តលើ សមាជិកភាពសហគមន៍ លក្ខន្តិកៈ សហគមន៍ និងបទបញ្ជាផ្ទៃក្នុង ផែនទីកន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ស្របតាមអនុក្រឹត្យស្តីពីការ គ្រប់គ្រងសហគមន៍នេសាទ និងគោលការណ៍ណែនាំសហគមន៍ ដែលបានប្រព្រឹត្តទៅនៅ ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ដែលបានចុះហត្ថលេខានៅថ្ងៃទី ខែ ឆ្នាំ ២០០ ក្នុងការបគល់ដែននេសាទ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋជាផ្លូវការពី ភាគី ៖ (ប្រធានការិយាល័យជលផលខេត្ត) ឱ្យទៅ ភាគី ២ (ប្រធានគណៈកម្មការសហគមន៍នេសាទ) ដោយធានានូវចិរភាពតាមរយៈការរៀបចំ សហគមន៍នេសាទ ។

ដោយផ្អែកលើសមិទ្ធិផលដូចបានរៀបរាប់ខាងលើ និងការប្រជុំឯកភាពគ្នារវាងគណៈកម្មការ និងសមាជិកសហគមន៍នេសាទរួចមក យើងខ្ញុំគណៈកម្មការតំណាងឱ្យសហគមន៍នេសាទ រហាលលិចស្រែះ សូមគោរពជូនឯកឧត្តមប្រធានរដ្ឋបាលជលផល នូវកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ដែលមានភ្ជាប់មកជាមួយនូវ បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ និងផែនទីកន្លែងសហគមន៍នេសាទ ដើម្បីពិនិត្យ និងសំរេច ដោយក្តីអនុគ្រោះ ។

យើងខ្ញុំគណៈកម្មការសហគមន៍នេសាទ រហាលលិចស្រែះ សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថានឹងដឹកនាំ គ្រប់គ្រងសហគមន៍នេសាទដោយគោរពទៅតាម លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍ កិច្ចព្រមព្រៀងកន្លែងនេសាទ ច្បាប់ និងលិខិតបទដ្ឋាននានាដែលទាក់ទងទៅនឹងវិស័យជលផល ។

បើសិនជាយើងខ្ញុំបានប្រព្រឹត្តអ្វីខុសនឹងកិច្ចព្រមព្រៀងខាងលើ យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ជាធរមាន ។

សូមឯកឧត្តមប្រធានមេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ភូមិស្រែខាងលិច ថ្ងៃទី 17 ខែ 10 ឆ្នាំ ២០០៨

ប្រធានសហគមន៍នេសាទ រហាលលិចស្រែះ

ឡុង សំបូរ

ព្រះរាជាណាច[redacted]កម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៙

**សហគមន៍នេសាទរហាលលិចស្រះ**

លេខៈ...០៣.......ស.ន.រ.ហ.ល.ស    រហាលលិចស្រះថ្ងៃទី..២៤....ខែ...០៣...ឆ្នាំ២០០៨

**គណៈកម្មការសហគមន៍នេសាទរហាលលិចស្រះ**

**សូមគោរពជូន**

**ឯកឧត្តមអភិបាលខេត្តបន្ទាយមានជ័យ**

**តាមរយៈ** : -លោកមេភូមិ ប៉ោយតាប៉ែន, ប៉ោយព្រីង, ស្រះគោកស្រុក, ស្រះខាងលិច, ស្រះខាងកើត

-លោកមេឃុំព្រះនេត្រព្រះ

-លោកអភិបាលស្រុកព្រះនេត្រព្រះ

-នាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ

-ឯកឧត្តមនាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប

**កម្មវត្ថុ** :សំណូមពរសុំពិនិត្យ និងសម្រេច លើគំនូសព្រាងផែនទីកន្លែងនេសាទសហគមន៍រហាលលិចស្រះ

**យោង** : -អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទលេខ២៥អនក្រ ចុះថ្ងៃទី២០ខែមិនាឆ្នាំ២០០៧

- ឆ្លងតាមការបិទផ្សាយជាសាធារណៈរយៈពេល ១ខែកន្លងមក

-ភាពចាំបាច់ របស់សហគមន៍នេសាទ

តាមកម្មវត្ថុ និងយោងគោរពជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាបថា គំនូសព្រាងផែនទីកន្លែងនេសាទសហគមន៍នេសាទរហាលលិចស្រះបានប្រសូត្រចេញតាមរយៈការពិគ្រោះយោបល់ ជាច្រើនដងជាមួយអ្នកពាក់ព័ន្ធ ការចុះកំណត់យកទីតាំងជាក់ស្តែង ដោយ GPS និងការបិទផ្សាយជា សាធារណៈ។

ដើម្បីឱ្យផែនទីនេះអាចប្រើប្រាស់ជាផ្លូវការ សហគមន៍នេសាទរហាលលិចស្រះសូមសំណូមពរឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

សូមឯកឧត្តម មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

**ជូនភ្ជាប់ជាមួយនូវ:**

-គំនូសព្រាងផែនទីកន្លែងនេសាទសហគមន៍នេសាទរហាលលិចស្រះ ចំនួន ០១ច្បាប់។

**ប្រធានគណៈកម្មការសហគមន៍នេសាទរហាលលិចស្រះ**

ឡើវ សំ អូរ

បានឃើញ និងសូមគោរពជូន

**លោកមេឃុំព្រះនេ—ព្រះ**

" ដើម្បីពិនិត្យ និងសំរួលបន្ត "

ថ្ងៃទី...25...ខែ...03...ឆ្នាំ២០០៨

លេខ :...07...មេភូមិប៉ោយប៉ែន

លេខ :...02...មេភូមិប៉ោយព្រីង

លេខ :...08...មេភូមិស្រះគោកស្រុក

លេខ :...05...មេភូមិស្រះខាងលិច

លេខ :...09...មេភូមិស្រះខាងកើត

លេខ:...២៧៧/៨៨...

បានឃើញ និងសូមគោរពជូន

**លោកអភិបាលស្រុកព្រះនេត្រព្រះ**

" ដើម្បីសូមពិនិត្យ និងសំរួលបន្ត "

ព្រះនេត្រព្រះ ថ្ងៃទី...26...ខែ...03...ឆ្នាំ២០០៨

**មេឃុំ**

ឡេង–ហ៊ុយ

លេខ:...១៤៦...ស.ជ.ភ/ស.ជ

បានឃើញ និងសូមគោរពជូន

**លោកប្រធានការិយាល័យដលផល**

" ដើម្បីសូមពិនិត្យ និងសំរួលបន្ត "

ព្រះនេត្រព្រះ ថ្ងៃទី......ខែ......ឆ្នាំ២០០៨

**អភិបាលស្រុក**

**ចុង ផែត**

លេខ:...០៨៦...ខវជ

បានឃើញ និងសូមគោរពជូន

**ឯកឧត្តមនាយអធិការដ្ឋានរដ្ឋបាលដលផលខាងជើងបឹងទន្លេសាប**

" ដើម្បីសូមមេត្តាពិនិត្យ ដោយក្តីអនុគ្រោះ "

បន្ទាយមានជ័យ ថ្ងៃទី......ខែ......ឆ្នាំ២០០៨

**នាយខណ្ឌរដ្ឋបាលជលផលបន្ទាយមានជ័យ**

លេខ:...១០៥...អរជ

បានឃើញ និងសូមគោរពជូន

**ឯកឧត្តមអភិបាលខេត្តបន្ទាយមានជ័យ**

" ដើម្បីសូមមេត្តាពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ "

កំពង់ធំ ថ្ងៃទី...០៣...ខែ...០៣...ឆ្នាំ២០០៨

**នាយអធិការដ្ឋានរដ្ឋបាលជលផលខាងជើងបឹងទន្លេសាប**

តាំង ឌិនថា

លេខ:...........

បានឃើញ និងឯកភាព

បន្ទាយមានជ័យ ថ្ងៃទី......ខែ......ឆ្នាំ២០០៨

**អភិបាលខេត្ត**

**ឡុង អឿន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុ

## ស្តីពី

មហាសន្និបាតវិសាមញ្ញ សហគមន៍នេសាទ

របស់សហគមន៍ ឃុំព្រះនេត្រព្រះ

ឆ្នាំពីរពាន់ប្រាំបី ខែ កក្កដា ថ្ងៃទី ... វេលាម៉ោងប្រាំបី និងសាមសិបនាទី ព្រឹក នៅសាលាបឋមសិក្សា ... ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។

បានបើកមហាសន្និបាតវិសាមញ្ញ សហគមន៍នេសាទ ដើម្បីពិភាក្សាលើរឿងសំខាន់ៗ ចំនួន ៥ គឺ

- បញ្ជាក់សមាជិកភាពសហគមន៍នេសាទ ។
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ។
- សម្គាល់ព្រំប្រទល់ដែនសហគមន៍នេសាទ ។
- កិច្ចព្រមព្រៀងតំបន់នេសាទសហគមន៍
- ផែនការគ្រប់គ្រងតំបន់នេសាទសហគមន៍

ក្រោមអធិបតីភាពរបស់លោក ... តាន់ អភិបាលរងស្រុកព្រះនេត្រព្រះ និងមន្ត្រីពាក់ព័ន្ធ ដឹកនាំដោយ ... ព្រមទាំងសមាជិកភាពចូលរួមបាន ។ លោក ... ប្រធាន ... លោកមេឃុំព្រះនេត្រព្រះ លោក ... ស្រុកព្រះនេត្រព្រះ ... លោក ... ៥ របស់សហគមន៍នេសាទ ... ក្រុមប្រឹក្សាឃុំ ... សមាជិកសហគមន៍ ... ។ ... និង ... ព្រមទាំង ... ។

សមាសភាពចូលរួមមានភ្ញៀវកិត្តិយស ... សមាជិកចាប់ផ្តើម លោក ... សមាជិកសហគមន៍នេសាទ ... បានបើកមហាសន្និបាត និង ... លោក ... ៥ ... ។

- ... លោក ... តាន់ អភិបាលរងស្រុក ព្រះនេត្រព្រះ និង ...

... បានបើកកិច្ចប្រជុំ ... សំណេះសំណាល ... មហាសន្និបាត ... មហាសន្និបាត ។

- មិត្តបង លោក ស. វ៉ែន ប្រធានក្រុមប្រឹក្សាភិបាល ដឹកនាំ ... ។

លោកបានដាក់ការងារ ទៅលើចំណុចទាំង ៥

1. បញ្ជីឈ្មោះ សមាជិក គាំទ្រ សមាគមន៍នេះ.

2. លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង សមាគមន៍នេះ.

3. សេចក្តីព្រាងថវិកា សមាគមន៍នេះ.

4. គម្រោងផ្សព្វផ្សាយ កម្មវិធីនៃការងារសមាគមន៍

5. វិធីការគ្រប់គ្រង កម្មវិធីនៃការងារសមាគមន៍

បន្ទាប់មកលោកបានបញ្ជាក់បន្ថែមពីការបង្កើតកម្មវិធី បន្តទៅទៀត និងបំណងរបស់សមាគមន៍ សមាការបង្កើតកម្មវិធី បន្តទៅទៀត ឲ្យបានល្អប្រសើរ ។

- មិត្តបង លោក. សេរី. សុខា. បានឡើងអាន សេចក្តីព្រាងការងារ និងបើកការបោះឆ្នោត ប្រជាពលរដ្ឋ ដែលចូលជាសមាជិក សមាគមន៍ ចំនួន. 1342 នាក់ ក្នុងនោះ 442 គ្រួសារ

សមាជិកអង្គប្រជុំ បានអនុម័តដោយចំនួន. មួយរយភាគរយ លើសមាជិក. 229/230

- មិត្តបង ស្រី ស៊ីន. ទូច. បានឡើងអាន សេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង និងជំពូកនិងមាត្រា ។

- មិត្តបង លោក ឈឿន. គា. បានឡើងអាន ការកែប្រែលក្ខន្តិកៈ

សមាជិកអង្គប្រជុំ បានអនុម័ត.

- មិត្តបង កញ្ញា. ចំ. ... បានឡើងអាន បទបញ្ជាផ្ទៃក្នុង និងជំពូកនិងមាត្រា ។

សមាជិកអង្គប្រជុំ បានអនុម័តដោយចំនួន មួយរយភាគរយ លើសមាជិក. 229/230.

- មិត្តបង លោក ម៉ុន. ហ៊ាំ បានឡើងអាន. សេចក្តីព្រាងថវិកា និងការព្រាងថវិកា ក្នុងការប្រើប្រាស់

សមាជិកអង្គប្រជុំ បានអនុម័តដោយចំនួន មួយរយ % លើសមាជិក ដែលមានវត្តមាន ...

ទាំងអស់

- មិត្តបង លោក. វ៉ាន់. ឈួន. បានឡើងអាន សេចក្តីព្រាង គម្រោង និងការផ្សព្វផ្សាយ កម្មវិធីនៃការងារ សមាគមន៍ និងការផ្សព្វផ្សាយ.

ដូចនេះ សមាជិកអង្គប្រជុំ បានពិភាក្សា និងអនុម័ត ...

... ទាំងអស់ ។

- មិត្តបង លោក ឈឿន គា. វិធីការគ្រប់គ្រង កម្មវិធីនៃការងារសមាគមន៍ ...

សមាជិក សមាជិកា. អង្គប្រជុំ បានអនុម័ត ... ទាំងអស់

ទាំងអស់

- មិត្តបង លោក ... បានឡើងអាន ...

អង្គប្រជុំ បានអនុម័ត ...

និងសមាគមន៍ ...

[illegible] ៥

-[illegible] ៤.

[illegible] ៤.

បានឃើញ និងឯកភាព.

[illegible]

ប្រធានអង្គប្រជុំ

[illegible]